00384619

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 10 / 2009
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/70

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 10 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>**
**<u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"</u>**
**<u>សាធារណៈ</u>**

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង
## ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៦៥

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង Natacha WEXELS-RISER

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Matteo Crippa, លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី, លោកស្រី Franziska Eckelmans |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde D'estmael, លោក សេង ប៊ុនឃាង, លោក Anees Ahmed (រសៀល), លោក Zachery Lampell, លោក ប៉ាក់ ចន្ទលីណូ, លោក ទី មុន្និន លោក ហួត វិចិត្រ, លោក ម៉ម ច័ន្ទវណ្ណៈ |

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្កេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux, លោក ចាន់ រ៉ាវុធ, លោកស្រី Héleyn Unac, លោក Alexandre Prezanti(វសៀល) |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ហុង គឹមសួន, លោកស្រី Fabienne Trusses-Naprous, លោក គឹម ម៉េងឃី, លោក Alain Werner, កញ្ញា ទី ស្រ៊ីនណា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Scott Bywater, លោកស្រី Julie Massé, លោក សាន គីរី, លោកស្រី ពេជ្រ ចរិយា |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.៣៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.០០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៣០ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីជូនដំណឹង និងសេចក្តីណែនាំទៅភាគី | អង្គជំនុំជម្រះ | ៩.១០ | ៩.២៤ |
| ការពិភាក្សាដេញដោលជាក់លាក់ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីការពារក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.២៥ | ១០.២៦ |
| សំណើសុំទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/32 | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ | ១០.២៧ | ១១.១៨ |
| សេចក្តីសម្រេចដោយផ្ទាល់មាត់ និងសេចក្តីណែនាំសម្រាប់សវនាការថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ | អង្គជំនុំជម្រះ | ១១.១៨ | ១១.២២ |
| ការកត់សម្គាល់ទៅលើសំណួរថាតើដើម | សហព្រះរាជអាជ្ញា | ១១.២៣ | ១១.៣៤ |

| | | | |
|---|---|---|---|
| បណ្តឹងរដ្ឋប្បវេណីអនុញ្ញាតិឲ្យសួរទៅជនជាប់ចោទ និងសាក្សីដែលកោះហៅទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទដែរឬទេ | | | |
| ការកត់សម្គាល់ទៅលើសំណួរថាតើដើមបណ្តឹងរដ្ឋប្បវេណីអនុញ្ញាតិឲ្យសួរទៅជនជាប់ចោទ និងសាក្សីដែលកោះហៅទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទដែរឬទេ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ និង ៤ (១១.៣៥ ដល់ ១១.៤២) ក្រុមទី៣(១១.៤៣ ដល់ ១១.៥២) ក្រុមទី១ (១១.៥២ ដល់ ១២.០៥) | ១១.៣៥ | ១២.០៥ |
| ការកត់សម្គាល់ទៅលើសំណួរថាតើដើមបណ្តឹងរដ្ឋប្បវេណីអនុញ្ញាតិឲ្យសួរទៅជនជាប់ចោទ និងសាក្សីដែលកោះហៅទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទដែរឬទេ | មេធាវីការពារក្តី | ១៣.៣៥ | ១៤.០១ |
| ការអានទាក់ទង នឹងកថាខណ្ឌ ១៦២ ដល់ ១៧០ នៃដីកាដំណោះស្រាយ | អង្គជំនុំជម្រះ | ១៥.០១ | ១៥.២៥ |
| ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងអត្តចរិតរបស់គាត់ | អង្គជំនុំជម្រះ | ១៥.២៥ | ១៦.២២ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**សេចក្តីជូនដំណឹង និងសេចក្តីណែនាំទៅភាគី**

អង្គជំនុំជម្រះបានផ្តល់ពត៏មាន និងសេចក្តីណែនាំទៅភាគីទាក់ទងនឹងការដាក់ភស្តុតាង (សូមមើលខាងក្រោម)

**ការពិភាក្សាដេញដោលលើការជំទាស់ទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវីការពារក្តីបានបន្តបង្ហាញពីការតវ៉ារបស់ខ្លួនទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/83, E2/49, E2/69, E2/73, E2/74 និង E2/75



E.C.C.C. TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសក្នុងការឆ្លើយតបចំពោះការតវ៉ាទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ។
មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ បានដកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីE2/77
មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ បានដកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/49

**សំណើសុំទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី** E2/32

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២បានស្នើសុំដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីE2/32 ទាក់ទងនឹងពត៌មានថ្មី។

**សេចក្តីសម្រេចដោយផ្ទាល់មាត់ និងសេចក្តីណែនាំសម្រាប់សវនាការនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩**

អង្គជំនុំជម្រះបានប្រកាសសេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើរួមគ្នាសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានទៅលើការផ្តន្ទាទោស(សូមមើលខាងក្រោម) និងបានអញ្ជើញឲ្យភាគីធ្វើការសង្កេតទៅលើសំណួរថាតើដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីដែលបានកោះហៅទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទដែរឬទេ។

**ការសង្កេតលើសំណួរថាតើដើមបណ្តឹងរដ្ឋប្បវេណីត្រូវអនុញ្ញាតិឲ្យតាំងសំណួរទៅជនជាប់ចោទ និងសាក្សី ដែលបានកោះហៅទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ**

សហព្រះរាជអាជ្ញាបានគាំទ្រដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីទាក់ទងនឹងអត្តចរិតជនជាប់ចោទ។
មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកអំណះអំណាងគាំទ្រសិទ្ធិរបស់ពួកគេ ក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីទាក់ទងនឹងអត្តចរិតជនជាប់ចោទ។
មេធាវីការពារក្តីបានលើកអំណះអំណាងថាដើមបណ្តឹងរដ្ឋប្បវេណីមិនគួរផ្តល់សិទ្ធិ ក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីទាក់ទងនឹងអត្តចរិតជនជាប់ចោទនោះទេ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. E.C.T.C

**សេចក្ដីសម្រេចលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ**

អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចរបស់ខ្លួនលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ (សូមមើលខាងក្រោម)។

**ការអានកថាខណ្ឌ ១៦២ ដល់ ១៧០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ**

ជាមួយនឹងសំណើរបស់មេធាវីការពារក្ដី អង្គជំនុំជម្រះបានអានកថាខណ្ឌ ១៦២ ដល់ ១៧០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

**ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងអត្តចរិតរបស់គាត់**

អង្គជំនុំជម្រះបានតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងអត្តចរិតរបស់គាត់។

**ការដកសំណើក្នុងការកោះហៅសាក្សី D14 ដោយមេធាវីការពារក្ដី**

មេធាវីការពារក្ដីបានជូនដំណឹងទៅអង្គជំនុំជម្រះថាពួកគេដកសំណើក្នុងការស្ដាប់សក្ខីកម្មសាក្សី D14។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសដ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត,សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E160.1 | IS 4.12 (ផ្នែកខ្លះ) | សៀវភៅ៖ ពេជ្ឈឃាតបាត់ខ្លួន Nic Dunlop | សាធារណៈ | 00369932-00370270 00370271-00370539 |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

**១. សេចក្ដីណែនាំទៅដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីការដាក់ភស្តុតាងបន្ថែម**

អង្គជំនុំជម្រះសាលាដំបូង សូមយោងលើការលើកឡើងរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើង ដោយផ្ទាល់មាត់ក្នុងសវនាការកាលពីព្រឹកថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៩ ជុំវិញគោលបំណង

ក្នុងដាក់ជូនដល់ អង្គជំនុំជម្រះនូវភស្តុតាងបញ្ជាក់ពីភាពពាក់ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងសំណុំរឿងលេខ ០០១ មួយចំនួនដែលត្រូវបានតវ៉ាដោយមេធាវីការពារក្តីពីភាពពាក់ព័ន្ធទាំងនេះ។

ដើម្បីអោយអង្គជំនុំជម្រះមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការពិនិត្យ និងសម្រេចទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានតវ៉ាទាំងនោះ ក៏ដូចជាដើម្បីធានាដល់ដំណើរការសវនាការអោយបានឆាប់រហ័ស និងប្រកបដោយភាពយុត្តិធម៌នោះ អង្គជំនុំជម្រះ៖

**សូមធ្វើការណែនាំដូចតទៅនេះ÷**

១.ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណាដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានជំទាស់តវ៉ាពីភាពស្របច្បាប់ក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ សូមដាក់នូវភស្តុតាងបន្ថែមជូនដល់អង្គជំនុំជម្រះដើម្បីបញ្ជាក់ពីភាពជាប់ពាក់ព័ន្ធទាំងឡាយរវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៃសំណុំរឿង០០១។

២.ប្រសិនអាចធ្វើទៅបាននោះ សូមភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់នូវភស្តុតាងទាំងនោះចំពោះមុខអង្គជំនុំជម្រះ យ៉ាងយូរបំផុតត្រឹមថ្ងៃព្រហស្បតិ៍ ទី ០៣ ខែកញ្ញា ឆ្នាំ ២០០៩ វេលាម៉ោង ៤ និង៣០ នាទីល្ងាច។

**២-សេចក្តីសម្រេចដោយផ្ទាល់មាត់និងសេចក្តីណែនាំសម្រាប់សវនាការថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩**

អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចរបស់ខ្លួន ត្រង់ផ្នែកនៃសេចក្តីសម្រេចទាក់ទងនឹង"សំណើរួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ ដែលសុំឲ្យចេញសេចក្តីសម្រេចលើសិទ្ធិរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស" ឯកសារលេខ E72 ដែលបានដាក់នៅថ្ងៃទី៩ ខែ មិថុនា ឆ្នាំ ២០០៩ ។

អង្គជំនុំជម្រះសូមប្រកាសនូវផ្នែកនៃសេចក្តីសម្រេចរបស់ខ្លួន ស្របតាម មាត្រា ១៤ (១) (ក) ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចខាងក្រោម :

តាមមតិភាគច្រើនរបស់ចៅក្រម និង មតិជំទាស់របស់ចៅក្រម Lavergne អង្គជំនុំជម្រះសម្រេចដូចខាងក្រោម៖



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

១. **បដិសេធ** សំណើរួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ ។

២. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនអនុញ្ញាតិឱ្យធ្វើសេចក្តីសន្និដ្ឋានទាក់ទងនិងការផ្តន្ទាទោស ដោយរួមទាំង

ក. សេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស

ខ. សេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់អំពីការផ្តន្ទាទោស និង

គ.សេចក្តីសន្និដ្ឋាន ឬការវាយតម្លៃនូវកត្តាទាំងឡាយដែលត្រូវសម្រេចសេចក្តីអំពីការផ្តន្ទាទោស មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺអនុញ្ញាតឱ្យយោងទៅលើអង្គហេតុទាំងនោះតែក្នុងករណីដែលត្រូវយោងទៅលើ ពិរុទ្ធភាព ឬ ភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។

សេចក្តីសម្រេចជាលាយលក្ខអក្សរ ដែលមានសំអាងហេតុនៃការឯកភាពភាគច្រើន និងការជំទាស់មួយផ្នែកនោះ នឹងចេញក្នុងរយៈពេលមួយសមស្រប ។

ដោយរំលឹកឡើងវិញនូវសេចក្តីសម្រេចដែលទើបតែបានប្រកាសខាងលើ អង្គជំនុំជម្រះសូមធ្វើការណែនាំដល់ភាគីឱ្យផ្តល់នូវអំណះអំណាងរបស់ខ្លួនទាក់ទងនិងបញ្ហាមួយចំនួនដូចខាងក្រោម៖

តើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានអនុញ្ញាតឱ្យសួរសំនួរដល់ជនជាប់ចោទ និងសាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មលើផ្នែកមួយនៃសវនាការដែលមានកម្មវត្ថុ-
"ការសួរសំណួរដល់សាក្សី និងអ្នកជំនាញ លើបញ្ហាទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" ដែរឬទេ? ដោយយោងតាមដីកាសម្រេចកំណត់កាលវិភាគសវនាការរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ។

អំណះអំណាងរបស់មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នឹងត្រូវលើកឡើងថ្ងៃនេះ បន្ទាប់ពីបានស្តាប់នូវការជំទាស់របស់មេធាវីការពារក្តី និងការឆ្លើយតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

**៣. សេចក្តីសម្រេចអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅជនជាប់ចោទ និង សាក្សីទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ**



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

ក្រោយពីបានស្តាប់ភាគីអំពីការសួរសំណួរដែលបានលើកឡើងកាលពីព្រឹកមិញទាក់ទងនឹង ថាតើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានអនុញ្ញាតឱ្យសួរសំនួរដល់ជនជាប់ចោទ និង សាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មលើផ្នែកមួយនៃសវនាការដែលមានកម្មវត្ថុ- "ការសួរសំណួរដល់សាក្សី និងអ្នកជំនាញ លើបញ្ហាទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" ដែរឬទេ?

តាមមតិភាគច្រើនរបស់ចៅក្រម និង មតិជំទាស់របស់ចៅក្រម Lavergne អង្គជំនុំជម្រះសម្រេច ដូចខាងក្រោម៖

ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតិឱ្យសួរជនជាប់ចោទពាក់ព័ន្ធនឹង អត្តចរិតនិង សាក្សី ដែលមានរហ័សនាម និងឈ្មោះ៖ KW-34 និង Francoise Seroni Guilbaud, D1, D2, D3, D4, D5, D6, Christopher Lapel, D8 និង D14 ។

សេចក្តីសម្រេចជាលាយលក្ខអក្សរ ដែលមានសំអាងហេតុនៃការឯកភាពភាគច្រើន និងការជំទាស់មួយ ផ្នែកនោះ នឹងចេញក្នុងរយៈពេលមួយសមស្រប ។

ការបែងចែកពេលវេលាសម្រាប់ព្រះរាជអាជ្ញា និងមេធាវីការពារ សួរសំនួរជនជាប់ចោទអំពីអត្តចរិត របស់គាត់គឺ ១ ម៉ោង និង ១៥ នាទីសម្រាប់ភាគីនីមួយៗ ។ ភាគីនឹងត្រូវបានជូនដំណឹងអំពីពេលវេលា សម្រាប់សាក្សីជាក់លាក់ នៅសប្តាហ៍ក្រោយ ។

បន្ទាប់ពីសម្រាកដើម្បីធ្វើការពិភាក្សា អង្គជំនុំជម្រះនឹងជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនទាក់ទង និងបញ្ហាខាងលើនេះ ថាតើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវអនុញ្ញាតិឱ្យសួរសំនួរដល់ ជនជាប់ចោទនិងសាក្សី ទាក់ទងនិងអត្តចរិតរបស់ជនជាប់ចោទដែរឬទេ ។ បន្ទាប់មកការសួរសំនួរ ដល់ជនជាប់ចោទអំពីអត្តចរិករបស់គាត់នឹងត្រូវចាប់ផ្តើម ។

៥.បង្គាប់ឱ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃច័ន្ទ ទី៣១ ខែសីហា ឆ្នាំ២០០៩ ។

<u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u>



TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E.C.C.C.

00384627

001/18-07-2007-ECCC/TC
E1/70

ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃច័ន្ទ ទី៣១ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។ SKV NWR.

ភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលវុទ្ធី Natacha WEXELS-RISER